**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងខេត្តសៀមរាប**

**សាលក្រមលេខ ៦២ "ច"/៦៤៧**

ចុះថ្ងៃទី០៤ ខែតុលា ឆ្នាំ២០២២

- សំណុំរឿងព្រហ្មទណ្ឌលេខ ៣៦២ ចុះថ្ងៃទី២០ ខែមីនា ឆ្នាំ២០២២
- សំណុំរឿងជំនុំជម្រះលេខ ៣៩២ ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០២២

# សាលក្រម

## ក្នុងនាមប្រជារាស្ត្រខ្មែរ

## សាលាដំបូងខេត្ត សៀមរាប

| | |
|---|---|
| កាលបរិច្ឆេទនៃសវនាការជាអសាធារណៈ | ៖ ថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២២ |
| សាលសវនាការ និងពេលវេលា | ៖ សាលលេខ ក១ រសៀល |
| កាលបរិច្ឆេទនៃការប្រកាសសាលក្រម | ៖ ថ្ងៃទី០៤ ខែតុលា ឆ្នាំ២០២២ |
| សាលសវនាការ និងពេលវេលា | ៖ សាលលេខ ក២ រសៀល |

ក្រោមសមាសភាពជំនុំជម្រះ

**ក្រុមប្រឹក្សាជំនុំជម្រះ**

លោកស្រី [redacted] ប្រធានក្រុមប្រឹក្សា ជំនុំជម្រះ

លោក [redacted] ចៅក្រមប្រឹក្សា ជំនុំជម្រះ

លោក [redacted] ចៅក្រមប្រឹក្សា ជំនុំជម្រះ

**តំណាងអយ្យការ**

លោក [redacted] ជាព្រះរាជអាជ្ញារង អមសាលាដំបូងខេត្តសៀមរាប

**ក្រឡាបញ្ជីសវនាការ**

លោកស្រី [redacted] ជាក្រឡាបញ្ជីសាលាដំបូងខេត្តសៀមរាប

**ដើម្បីជំនុំជម្រះ និងប្រកាសសាលក្រមលើ**

សំណុំរឿងព្រហ្មទណ្ឌលេខ ៣៦២ ចុះថ្ងៃ២០ ខែមីនា ឆ្នាំ២០២២ ដែលមានជនជាប់ចោទ៖

**១**-ឈ្មោះ [redacted] **គីម** ភេទប្រុស អាយុ២២ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ ទីកន្លែងកំណើតនៅភូ[redacted] ខេត្តព្រះវិហារ ទីលំនៅមុនពេលឃាត់ខ្លួននៅភូមិចុងកៅស៊ូ សង្កាត់ស្លក្រាម ក្រុងសៀមរាប ខេត្តសៀមរាប កម្រិតវប្បធម៌ថ្នាក់ទី៨ មុខរបរ ជាងឈើ នៅលីវ ឪពុកឈ្មោះ[redacted] គា "រស់" ម្តាយឈ្មោះ[redacted] ស្រីជា "រស់" ទោសពីមុន ធ្លាប់ជាប់ពន្ធនាគារ ២ឆ្នាំ ៦ខែ ពីបទល្មើសគ្រឿងញៀន។

ដីកាបង្គាប់ឲ្យឃុំខ្លួន លេខ ២១០ យខ/៣ ចុះថ្ងៃទី២០ ខែមីនា ឆ្នាំ២០២២។



Scanned with CamScanner

២-ឈ្មោះ [redacted] លីយ ហៅ ឡុប លើយ ភេទប្រុស អាយុ១៧ឆ្នាំ កើតនៅថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០០៤ ជនជាតិខ្មែរ សញ្ជាតិខ្មែរ ទីកន្លែងកំណើតនៅភូមិ[redacted] ខេត្តសៀមរាប ទីលំនៅមុនពេលឃាត់ខ្លួននៅភូមិ[redacted] ខេត្តសៀមរាប កម្រិតវប្បធម៌ថ្នាក់ទី២ មុខរបរ កម្មករសំណង់ នៅលីវ ឪពុកឈ្មោះ [redacted] ឡុប "រស់" ម្ដាយឈ្មោះ [redacted] បៃ "រស់" ទោសពីមុន គ្មាន ជាអនីតិជន។

ដីកាបង្គាប់ឲ្យឃុំខ្លួន លេខ ២០៩ ឃខ/៣ ចុះថ្ងៃទី២០ ខែមីនា ឆ្នាំ២០២២។

មានលោកស្រី ខេង បូរណ៍ច័ន្ទគារ ជាមេធាវីការពារសិទ្ធិ។

**ត្រូវបានដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យពីបទ** "ជាត់ចែងឱ្យប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន" ប្រព្រឹត្តនៅ ភូមិតាវៀន សង្កាត់សាលាកំរើក ក្រុងសៀមរាប ខេត្តសៀមរាប កាលពីថ្ងៃទី១៨ ខែមីនា ឆ្នាំ២០២២ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងឱ្យផ្ដន្ទាទោសតាមបញ្ញត្តិមាត្រា ៤២ កថាខណ្ឌ១,២ នៃច្បាប់ស្ដីពីការត្រួតពិនិត្យគ្រឿងញៀន។

- បានឃើញ ដីកាសន្និដ្ឋានស្ថាពរលេខ ៣៥១ អយខ/២០២២ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០២២ របស់អយ្យការអមសាលាដំបូង ខេត្តសៀមរាប។

- បានឃើញ ដីកាសម្រេចបញ្ជូនសំណុំរឿងទៅជំនុំជម្រះ លេខ ២៤៣៧ ពស.ព្រស/៣ ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០២២ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូង ខេត្តសៀមរាប។

- បានឃើញ ដីកាចាត់តាំងចៅក្រមជំនុំជម្រះលេខ លេខ ៤១៦ ពស.ព្រជ (ក) ចុះថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០២២ របស់ប្រធានសាលាដំបូង ខេត្តសៀមរាប។

- បានឃើញ ដីកាផ្ដល់ដំណឹងកាលបរិច្ឆេទសវនាការ ដែលធ្វើឡើងដោយមានអនុលោមតាមមាត្រា ២៩២ និងមាត្រាបន្តបន្ទាប់នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

## អង្គហេតុដែលប្ដឹងមកតុលាការ

កាលពីថ្ងៃទី១៨ ខែមីនា ឆ្នាំ២០២២ វេលាម៉ោង២៣ និង៣០នាទី ស្ថិតនៅភូមិតាវៀន សង្កាត់សាលាកំរើក ក្រុងសៀមរាប ខេត្តសៀមរាប ឈ្មោះ [redacted] គីម ភេទប្រុស និងឈ្មោះ [redacted] លីយ ហៅ [redacted] លើយ ភេទប្រុស ត្រូវបានកម្លាំងការិយាល័យប្រឆាំងគ្រឿងញៀន នៃកងរាជអាវុធហត្ថខេត្តសៀមរាប ធ្វើការឃាត់ខ្លួន និងឆែកឆេរឃើញថ្នាំញៀន ចំនួន ១កញ្ចប់ ទម្ងន់ ០,៥៨ ក្រាម នៅក្នុងហោប៉ៅរបស់ឈ្មោះ [redacted] គីម។ ក្រោយមកសមត្ថកិច្ចបានធ្វើការសាកសួរលើឈ្មោះ [redacted] គីម និងឈ្មោះ [redacted] លីយ ហៅ [redacted] លើយ ពួកគេបានឆ្លើយសារភាពថា ពួកគេពិតជាបានចូលប្រាក់គ្នាក្នុងម្នាក់ៗ ចំនួន ២០.០០០ (ពីរម៉ឺន) រៀល ដើម្បីទិញថ្នាំញៀនយកទៅប្រើប្រាស់រួមគ្នាពិតមែន តែមិនទាន់បានប្រើប្រាស់ផងក៏ត្រូវសមត្ថកិច្ចឃាត់ខ្លួន និងដកហូតបានថ្នាំញៀនតែម្ដង។ ពេលសមត្ថកិច្ចឃាត់ខ្លួន បានធ្វើតេស្តទឹកនោមរកសារធាតុញៀនលើឈ្មោះ [redacted] គីម និងឈ្មោះ [redacted] លើយ លទ្ធផលវិជ្ជមាន។

## នាពេលសវនាការ

-ជនជាប់ចោទឈ្មោះ [redacted] លីយ ហៅ [redacted]លើយ បានឆ្លើយថា ខ្លួនស្គាល់ឈ្មោះ [redacted] គីម ដោយឈ្មោះ [redacted]គីម គាត់ធ្វើការនៅកន្លែងជាមួយគ្នា ដោយខ្លួនជាជាងសំណង់ ចំណែកឈ្មោះ [redacted] គីម ជាជាងឈើ។ ខ្លួនធ្វើការជាងសំណង់នៅក្រោយផ្លូវផ្សារលើខេត្តសៀមរាប បានរយៈពេល៣ឆ្នាំ មកហើយ ដោយបានប្រាក់ប្រចាំថ្ងៃ ១ថ្ងៃ ចំនួន ៤០.០០០ (បួនម៉ឺន) រៀល។ ចំពោះចម្លើយនៅដំណាក់កាលមន្ត្រីនគរបាលយុត្តិធម៌ និងដំណាក់កាលកាលអយ្យការ ខ្លួនទទួលស្គាល់ និងសុំរក្សាទុកនៅដដែល។ ចំពោះថ្នាំញៀនចំនួន ១ (មួយ) កញ្ចប់ ដែលសមត្ថកិច្ចដកហូតបាននោះ គឺដកហូតពីឈ្មោះ [redacted] គីម ជាថ្នាំញៀនដែលខ្លួនបានចូលលុយគ្នាជាមួយឈ្មោះ [redacted]គីម ក្នុងម្នាក់ៗ ២០.០០០ (ពីរម៉ឺន) រៀល ទិញបានថ្នាំញៀនមួយកញ្ចប់ តម្លៃ ៤០.០០០ (បួនម៉ឺន) រៀល។ ខ្លួនចេះប្រើប្រាស់ថ្នាំញៀនបានរយៈពេលប្រហែល១ឆ្នាំមកហើយ។ ពេលចង់ប្រើប្រាស់គ្រឿងញៀន ពួកខ្លួនប្រើប្រាស់ជុំគ្នា ធ្វើឧបករណ៍ប្រើប្រាស់ខ្លួនឯងជាមួយគ្នា។ ខ្លួនប្រើប្រាស់គ្រឿងញៀន ដោយសារធ្វើការច្រើនអស់កម្លាំង ខ្លួនចង់ឈប់ប្រើហើយ។ ខ្លួនអ្នកទូរស័ព្ទទៅអ្នកលក់ ឈ្មោះ [redacted] អត់ស្គាល់ទេ។ ថ្នាំញៀនមួយកញ្ចប់ប្រើបានពីរទៅបីដង ពេលប្រើសល់ទុកប្រើប្រាស់ជុំគ្នាទៀត។ ចំពោះម៉ូតូម្ដាយខ្លួនយកវិញហើយ។

-ជនជាប់ចោទឈ្មោះ [redacted] គីម បានឆ្លើយថា សមត្ថកិច្ចឃាត់ខ្លួន កាលពីថ្ងៃទី១៨ ខែមីនា ឆ្នាំ២០២២ ដោយសារខ្លួនមានការពាក់ព័ន្ធនឹងករណីគ្រឿងញៀន ដោយខ្លួនបានចូលលុយគ្នាជាមួយ ឈ្មោះ [redacted] លើយ ក្នុងម្នាក់ៗចំនួន ២០.០០០ (ពីរម៉ឺន) រៀល ទិញគ្រឿងញៀនមួយកញ្ចប់តម្លៃ ៣០.០០០ (បីម៉ឺន) រៀល ដោយឈ្មោះ [redacted]លើយ បានយកលុយនោះទៅទិញថ្នាំញៀនពីមនុស្សមិនស្គាល់ឈ្មោះ តាមរយៈទូរស័ព្ទមិនចាំលេខ យកគ្រឿងញៀនក្រោយផ្សារលើ និងហុចលុយឲ្យគេ មិនស្គាល់មុខអ្នកលក់ទេ ខ្លួនបានសហការណ៍ជាមួយសមត្ថកិច្ចរកអ្នកលក់ដែរ ប៉ុន្តែរកមិនឃើញ។ បន្ទាប់ពីទិញថ្នាំញៀនបានហើយ ក៏បានជិះម៉ូតូត្រឡប់មកវិញ នៅពេលដែលកំពុងជិះម៉ូតូតាមផ្លូវ ត្រឡប់មកវិញនោះ ក៏ត្រូវបានសមត្ថកិច្ចឃាត់ខ្លួន ឆែកឆេរ និងបានដកហូតថ្នាំញៀន មួយកញ្ចប់ ក្នុងហោប៉ៅខោរបស់ខ្លួន ដោយឈ្មោះ លើយ ជាអ្នកឧប។ ខ្លួនស្គាល់ឈ្មោះ [redacted] លើយ រយៈពេលជិតមួយឆ្នាំមកហើយ គាត់ធ្វើការនៅកន្លែងជាមួយគ្នា ដោយខ្លួនជាជាងឈើ ចំណែកគាត់ជាជាងសំណង់។ ខ្លួនធ្លាប់ប្រើប្រាស់ថ្នាំញៀនជាមួយឈ្មោះ [redacted] លើយ បានចំនួន ២ដងដែរ ដោយចូលលុយគ្នាជាមួយឈ្មោះ [redacted] លើយ ដើម្បីទិញយកទៅប្រើប្រាស់នៅក្នុងព្រៃ ស្រុកស្វាយលើ បានចំនួនបីដង និងធ្លាប់ប្រើប្រាស់ថ្នាំញៀនប្រហែល៣ដងម្នាក់ឯង។ មូលហេតុដែលខ្លួនប្រើប្រាស់ថ្នាំញៀន គឺដើម្បីយកកម្លាំងទៅធ្វើការជាជាងឈើ។ ពេលសមត្ថកិច្ចឃាត់ខ្លួនដកហូតបានថ្នាំញៀនចំនួន ១កញ្ចប់។

## សេចក្ដីសន្និដ្ឋានប្ដឹងសុំរបស់តំណាងអយ្យការ

-ក្រោយពីបានស្ដាប់ចម្លើយសារភាពរបស់ជនជាប់ចោទ ឃើញថា ជនជាប់ចោទបានសហការណ៍គ្នា ដើម្បីទិញគ្រឿងញៀនប្រើប្រាស់ជុំគ្នា ដោយឈ្មោះ [redacted] លើយ ជាអ្នកទាក់ទងទិញគ្រឿងញៀន និងជាអ្នកឧបទៅទិញ ចំណែកឈ្មោះ [redacted] គីម ជាអ្នករក្សាទុកគ្រឿងញៀននោះ និងបានធ្វើឧបករណ៍ប្រើប្រាស់ជុំគ្នា ដូច្នេះ តំណាងអយ្យការរក្សាបទចោទប្រកាន់ និងប្ដឹងសុំតុលាការសម្រេចផ្ដន្ទាទោសជនល្មើសតាមច្បាប់។

## សេចក្ដីសន្និដ្ឋានការពាររបស់មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ

-ខ្លួនបានដាក់សេចក្ដីសន្និដ្ឋានជូនតុលាការរួចហើយ និងសុំបន្ថែមស្នើសុំក្រុមប្រឹក្សាសម្រេចឲ្យកូនក្ដីខ្លួនរួចផុតពីបទចោទ ព្រោះគ្មានភស្តុតាងគ្រប់គ្រាន់ចោទប្រកាន់លើកូនក្ដីខ្លួន ដោយគ្រាន់តែសំអាងលើថ្នាំញៀនមួយកញ្ចប់នោះទេ ហើយខ្លួនក៏ធ្លាប់ស្នើសុំចៅក្រមស៊ើបសួរឲ្យបំពេញកិច្ចស៊ើបសួរដែរ ប៉ុន្តែមិនទាន់បានបំពេញ។ កូនក្ដីខ្លួនអត់បានប្រើប្រាស់ កូនក្ដីខ្លួនជាអនីតិជន តាមច្បាប់អនីតិជនឲ្យគាត់ត្រឡប់ទៅមណ្ឌលកែប្រែ ព្រោះគាត់ក៏មានចេតនាចង់ឈប់ដែរ ដោយការយល់ដឹងរបស់គាត់នៅមានកម្រិត ហើយមន្ត្រីនគរបាលយុត្តិធម៌អត់បានចូលរួមក្នុងសវនាការនេះទេ។ តាមមាត្រា ៣៨ និងមាត្រា ៣៥១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ វិមតិសង្ស័យជាប្រយោជន៍ដល់ជនជាប់ចោទ ដូច្នេះ ស្នើសុំតុលាការសម្រេចឲ្យកូនក្ដីខ្លួនរួចផុតពីបទចោទ។

## សិទ្ធិនិយាយសំដីចុងក្រោយរបស់ជនជាប់ចោទ

-ជនជាប់ចោទឈ្មោះ [redacted] លើយ និងឈ្មោះ [redacted] គីម សំណូមពរ តុលាការសម្រេចឲ្យពួកខ្លួនរួចផុតពីបទចោទប្រកាន់។

- ក្រោយពី បានស្ដាប់ចម្លើយរបស់ជនជាប់ចោទ
- ក្រោយពី បានស្ដាប់សេចក្ដីសន្និដ្ឋានប្ដឹងសុំរបស់តំណាងអយ្យការ
- ក្រោយពី បានស្ដាប់សេចក្ដីសន្និដ្ឋានការពាររបស់មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ
- ក្រោយពី បានពិនិត្យលើភស្តុតាងឯកសារផ្សេងៗក្នុងសំណុំរឿង

## ក្រោយពីបានពិភាក្សា និងពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

## សំអាងហេតុ

**១**-សាលាដំបូង ខេត្តសៀមរាប បានទទួលសំណុំរឿងព្រហ្មទណ្ឌលេខ ៣៦២ ចុះថ្ងៃទី២០ ខែមីនា ឆ្នាំ២០២២ ដែលមានជនជាប់ចោទឈ្មោះ [redacted] គីម ភេទប្រុស អាយុ២២ឆ្នាំ និងឈ្មោះ [redacted] លីយ ហៅ [redacted] លើយ ភេទប្រុស អាយុ១៧ឆ្នាំ (មានអត្តសញ្ញាណដូច ខាងលើ) មកជំនុំជម្រះពីបទ "ចាត់ចែងឱ្យប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន" ប្រព្រឹត្តនៅភូមិតាវៀន សង្កាត់សាលាកំរើក ក្រុងសៀមរាប ខេត្តសៀមរាប កាលពីថ្ងៃទី១៨ ខែមីនា ឆ្នាំ២០២២ បទល្មើសព្រហ្មទណ្ឌដែលមានចែង

និងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤២ កថាខណ្ឌទី១,២ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន តាមដីកាសម្រេចបញ្ជូនសំណុំរឿងទៅជំនុំជម្រះ លេខ ២៤៣៧ ពស.ព្រស/ញ ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០២២ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូង ខេត្តសៀមរាប តាមមាត្រា ២៩១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ដែលនាំឱ្យសាលាដំបូង ខេត្តសៀមរាប មានសមត្ថកិច្ចក្នុងការជំនុំជម្រះ។

**២**-តាមដីកាសម្រេចបញ្ជូនសំណុំរឿងទៅជំនុំជម្រះ លេខ ២៤៣៧ ពស.ព្រស/ញ ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០២២ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូង ខេត្តសៀមរាប ដែនកំណត់នៃការប្តឹងមកតុលាការចំពោះអង្គហេតុ តាមមាត្រា ៣៤៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ និងដែនកំណត់នៃការប្តឹងមកតុលាការចំពោះបុគ្គល តាមមាត្រា ៣៤៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នាំឱ្យសាលាដំបូង ខេត្តសៀមរាប មានសមត្ថកិច្ចក្នុងការជំនុំជម្រះលើអង្គ ហេតុដែលប្តឹងមកតុលាការ និងចំពោះជនជាប់ចោទឈ្មោះ [redacted] គីម ភេទប្រុស អាយុ២២ឆ្នាំ និងឈ្មោះ [redacted] លីយ ហៅ [redacted] លើយ ភេទប្រុស អាយុ១៧ឆ្នាំ (ដូចមានអត្តសញ្ញាណខាងលើ)។

**៣**-តាមចម្លើយសារភាពរបស់ជនជាប់ចោទឈ្មោះ [redacted] គីម និងឈ្មោះ [redacted] លីយ ហៅ ឡុប លើយ បានឆ្លើយបញ្ជាក់ដូចគ្នាថា ថ្នាំញៀនដែលសមត្ថកិច្ចដកហូត គឺជារបស់ពួកខ្លួន ដែលបានចូលលុយគ្នាទិញទុកប្រើប្រាស់រួមគ្នា ប្រាកដមែន ដែលចម្លើយនេះស៊ីសង្វាក់គ្នាទៅនឹងភស្តុតាង បញ្ជាក់បានថា អង្គហេតុដែលតំណាងអយ្យការបានប្តឹងមកនោះ គឺជាការពិត តុលាការយល់ឃើញថា មានអំពើល្មើស តាមបញ្ញត្តិមាត្រា ៤២ កថាខណ្ឌទី១,២ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

**៤**-តាមការអះអាងរបស់ជនជាប់ចោទ អំពីអង្គហេតុនៃការ "ចាត់ចែងឱ្យប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន" ដែលជាមូលដ្ឋាននៃការចោទប្រកាន់ នៅក្នុងដំណាក់កាលនីតិវិធី និងនាពេលសវនាការ និងជាមូលដ្ឋាននៃធាតុផ្សំបទល្មើស "ចាត់ចែងឱ្យប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន" គឺមានភាពច្បាស់លាស់។ តុលាការយល់ឃើញថា អង្គហេតុនៃការ "ចាត់ចែងឱ្យប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន" ខាងលើ បានបញ្ជាក់បង្ហាញដោយភស្តុតាងស៊ីសង្វាក់ ដែលនាំឱ្យតុលាការ អាចជឿពីអត្ថិភាពនៃអង្គហេតុនេះ ប្រាកដមែន។

**៥**-តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានប្តឹងសុំ តុលាការផ្តន្ទាទោសជនជាប់ចោទតាមច្បាប់ ឃើញថា មានលក្ខណៈត្រឹមត្រូវ តុលាការនឹងពិនិត្យ និងសម្រេច តាមនីតិវិធីច្បាប់។

**៦**-មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទបានធ្វើសេចក្តីសន្និដ្ឋានការពារស្នើសុំ ឲ្យតុលាការសម្រេចឲ្យកូនក្តីខ្លួនរួចផុតពីបទចោទប្រកាន់ ឃើញថា មានលក្ខណៈមិនត្រឹមត្រូវ តុលាការនឹងមិនពិនិត្យ និងសម្រេច តាមការស្នើសុំនោះទេ ព្រោះជនជាប់ចោទ បានសារភាពអំពីអំពើល្មើសរបស់ខ្លួនរួចហើយ។



Scanned with CamScanner

៧-មានបន្ទុក និងភស្តុតាងគ្រប់គ្រាន់បង្ហាញពីពិរុទ្ធភាពរបស់ជនជាប់ចោទឈ្មោះ គា គីម ភេទប្រុស អាយុ២២ឆ្នាំ និងឈ្មោះ [redacted] លីយ ហៅ [redacted] លើយ ភេទប្រុស អាយុ១៧ឆ្នាំ (មានអត្តសញ្ញាណដូច ខាងលើ) មកជំនុំជម្រះពីបទ "ចាត់ចែងឱ្យប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន" ប្រព្រឹត្តនៅ ភូមិតាវៀន សង្កាត់សាលាកំរើក ក្រុងសៀមរាប ខេត្តសៀមរាប កាលពីថ្ងៃទី១៨ ខែមីនា ឆ្នាំ២០២២ បទល្មើសព្រហ្មទណ្ឌដែលមានចែងនិងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤២ កថាខណ្ឌទី១,២ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

៨-ដីកាបង្គាប់ឲ្យរក្សាទុកវត្ថុតាងចាប់យក លេខ ១១០/២០២២ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០២២ ឃើញថា វត្ថុតាងដែលចាប់យកមាន ទូរស័ព្ទដៃម៉ាក NOKIA ចុចពិល ពណ៌ខៀវ ចំនួន ១ (មួយ) គ្រឿង គប្បី សម្រេចរឹបអូស។

៩-តាមលទ្ធផលកោសលវិច័យគ្រឿងញៀន លេខ ៣៦៥៤៨/២២ ម.ព.អ.ជ.ប.គ.ញ ចុះថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០២២ បានសន្និដ្ឋានថា សំណាកជាគ្រឿងញៀនប្រភេទក្រាមម្សៅថ្លា ឈ្មោះ មេតំហ្វេតាមីន ដែលមានកម្រិតភាពសុទ្ធ ៧៣.៨៩ ភាគរយនៃទម្ងន់សរុប។

## ហេតុដូច្នេះ សម្រេច

**I-ផ្តន្ទាទោស**ជនជាប់ចោទ៖

**១.**ឈ្មោះ [redacted] គីម ភេទប្រុស អាយុ២២ឆ្នាំ (មានអត្តសញ្ញាណដូច ខាងលើ) ដាក់ពន្ធនាគារកំណត់រយៈពេល ០២ (ពីរ) **ឆ្នាំ អនុវត្តទោសពន្ធនាគាររយៈពេល ១ (មួយ) ឆ្នាំ និង ០៦ (ប្រាំមួយ) ខែ ទោសសល់ពីនេះ ព្យួរធម្មតា។**

**២.**ឈ្មោះ [redacted] លីយ ហៅ ឡប លើយ ភេទប្រុស អាយុ១៧ឆ្នាំ ជាអនីតិជន (មានអត្តសញ្ញាណដូច ខាងលើ) ដាក់ពន្ធនាគារកំណត់រយៈពេល ០១ **(មួយ) ឆ្នាំ អនុវត្តទោសពន្ធនាគាររយៈពេល ៨ (ប្រាំបី) ខែ ទោសសល់ពីនេះ ព្យួរធម្មតា ។**

**ពីបទ** "ចាត់ចែងឱ្យប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន" ប្រព្រឹត្តនៅ ភូមិតាវៀន សង្កាត់សាលាកំរើក ក្រុងសៀមរាប ខេត្តសៀមរាប កាលពីថ្ងៃទី១៨ ខែមីនា ឆ្នាំ២០២២ បទល្មើសព្រហ្មទណ្ឌដែលមានចែងនិងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤២ កថាខណ្ឌទី១, ២ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

**II-វត្ថុតាងដែលចាប់យកមាន៖** ទូរស័ព្ទដៃម៉ាក NOKIA ចុចពិល ពណ៌ខៀវ ចំនួន ១ (មួយ) គ្រឿង សម្រេចរឹបអូស។

-សាលក្រមនេះ ជំនុំជម្រះ និងប្រកាសជាសាធារណៈ ចំពោះមុខជនជាប់ចោទ។

-ទុកសិទ្ធិប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់។

**ក្រឡាបញ្ជីសវនាការ** **ចៅក្រមប្រឹក្សា** **ចៅក្រមប្រឹក្សា** **ប្រធានក្រុមប្រឹក្សា**

**ហត្ថលេខា និងត្រា** [redacted]

---

**បានឃើញ**

ថ្ងៃអង្គារ ៩កើត ខែអស្សុជ ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦

សៀមរាប ថ្ងៃទី០៤ ខែតុលា ឆ្នាំ២០២២

**ប្រធានក្រុមប្រឹក្សា**

[redacted]

**បានចម្លងត្រឹមត្រូវតាមច្បាប់ដើម**

ថ្ងៃអង្គារ ៩កើត ខែអស្សុជ ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦

សៀមរាប ,ថ្ងៃទី០៤ ខែតុលា ឆ្នាំ២០២២

**ក្រឡាបញ្ជី**

[redacted]

បានថតចម្លងត្រឹមត្រូវចេញពី
ច្បាប់ដើមដោយម៉ាស៊ីនហ្វូតូកូពី
សៀមរាប ថ្ងៃទី ២៧ ខែ មករា ឆ្នាំ២០២៣

**ក្រឡាបញ្ជី**

[redacted]